**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ** :...៥០.....អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិក្រុង ស្រុក

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ៣៦ អនក្រ.បក ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១២ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិក្រុង ស្រុក
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

**ជំពូកទី១**

**បទប្បញ្ញត្តិទូទៅ**

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងកំណត់ពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិក្រុង ស្រុក សម្រាប់ថេរវេលា ០៥(ប្រាំ)ឆ្នាំ ពីឆ្នាំ២០១៩ ដល់ ឆ្នាំ២០២៣។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលដៅកំណត់អត្រានៃចំណូលចរន្តថវិការដ្ឋដែលត្រូវបានផ្ទេរប្រចាំឆ្នាំជូនមូលនិធិក្រុង ស្រុក និងកំណត់រូបមន្ត សន្ទស្សន៍នៃការបែងចែកមូលនិធិក្រុង ស្រុក ព្រមទាំងកម្មវិធីនៃការផ្ទេរឥណទាន និងសាច់ប្រាក់ទៅឱ្យរដ្ឋបាលក្រុង ស្រុក។

**មាត្រា ៣.-**

អនុក្រឹត្យនេះមានវិសាលភាពគ្របដណ្ដប់លើរដ្ឋបាលក្រុង ស្រុកទាំងអស់ទូទាំងប្រទេស។

**ជំពូកទី២**

**ប្រភពធនធាន និងការគ្រប់គ្រងមូលនិធិក្រុង ស្រុក**

**មាត្រា ៤.-**

កម្រិតនៃការផ្ទេរពីថវិកាជាតិទៅក្នុងគណនីមូលនិធិក្រុង ស្រុកត្រូវកំណត់សម្រាប់ថេរវេលាចំនួនប្រាំឆ្នាំ ឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣ ដោយគិតជាសមាមាត្រលើចំណូលចរន្តថវិកាជាតិមានដូចខាងក្រោម ÷

- ឆ្នាំថវិកា២០១៩ មានចំនួន ១,១ ភាគរយនៃចំណូលចរន្តថវិកាជាតិដែលបានអនុម័តឆ្នាំ២០១៨
- ឆ្នាំថវិកា២០២០ មានចំនួន ១,២ ភាគរយនៃចំណូលចរន្តថវិកាជាតិដែលបានអនុម័តឆ្នាំ២០១៩
- ឆ្នាំថវិកា២០២១ មានចំនួន ១,៣ ភាគរយនៃចំណូលចរន្តថវិកាជាតិដែលបានអនុម័តឆ្នាំ២០២០
- ឆ្នាំថវិកា២០២២ មានចំនួន ១,៤ ភាគរយនៃចំណូលចរន្តថវិកាជាតិដែលបានអនុម័តឆ្នាំ២០២១ និង
- ឆ្នាំថវិកា២០២៣ មានចំនួន ១,៥ ភាគរយនៃចំណូលចរន្តថវិកាជាតិដែលបានអនុម័តឆ្នាំ២០២២។

**ជំពូកទី៣**

**ការបែងចែក ការផ្ទេរ និងការប្រើប្រាស់ធនធានមូលនិធិក្រុង ស្រុក**

**មាត្រា ៥.-**

ធនធានមូលនិធិក្រុង ស្រុកត្រូវបែកចេញជាពីរសមាសភាគដូចខាងក្រោម ÷

- សមាសភាគប្រតិបត្តិការរដ្ឋបាលទូទៅ និង
- សមាសភាគអភិវឌ្ឍន៍មូលដ្ឋាន

ទំហំធនធាននៃសមាសភាគនីមួយៗនៃមូលនិធិក្រុង ស្រុកត្រូវកំណត់ដូចខាងក្រោម ÷

ក). ទំហំធនធាននៃសមាសភាគប្រតិបត្តិការរដ្ឋបាលទូទៅត្រូវបានកំណត់ដោយផ្អែកលើឯកតារង្វាស់ និងនិយាមដូចខាងក្រោម ÷

- ចំនួនសរុបនៃសមាជិកក្រុមប្រឹក្សាក្រុង ស្រុកនិងប្រាក់ឧបត្ថម្ភរបស់សមាជិកក្រុមប្រឹក្សាក្រុង ស្រុក
- ចំនួនសរុបនៃអភិបាល អភិបាលរង និងបុគ្គលិករបស់រដ្ឋបាលក្រុង ស្រុក និងប្រាក់បៀវត្ស សម្រាប់ប្រភេទនីមួយៗ និង
- គម្រោងចំណាយប្រតិបត្តិការរដ្ឋបាលផ្សេងៗទៀតមិនឲ្យលើសពី ២៥ ភាគរយនៃធនធានមូលនិធិសរុប *ដក* ចំនួនសរុបប្រាក់ឧបត្ថម្ភរបស់សមាជិកក្រុមប្រឹក្សាក្រុង ស្រុក និងប្រាក់បៀវត្សរបស់អភិបាល អភិបាលរង និងបុគ្គលិករបស់រដ្ឋបាលក្រុង ស្រុក។

ខ). ទំហំធនធាននៃសមាសភាគអភិវឌ្ឍន៍មូលដ្ឋាន *ស្មើនឹង* ធនធានវិភាជន៍សរុប *ដក* ទំហំធនធាននៃសមាសភាគប្រតិបត្តិការរដ្ឋបាលទូទៅ។

**មាត្រា ៦.-**

ធនធាននៃសមាសភាគទាំងពីរនៃមូលនិធិក្រុង ស្រុកត្រូវបានបែងចែកទៅឲ្យរដ្ឋបាលក្រុង ស្រុកនីមួយៗ ស្របតាមវិធានដូចខាងក្រោម ÷

១). ធនធាននៃសមាសភាគប្រតិបត្តិការរដ្ឋបាលទូទៅត្រូវបានវិភាជន៍ទៅរដ្ឋបាលក្រុង ស្រុកនីមួយៗ ដោយអនុលោមតាមនិយាមដូចខាងក្រោម ÷

ក). ចំណាយប្រាក់ឧបត្ថម្ភសមាជិកក្រុមប្រឹក្សាក្រុង ស្រុក

ខ). ចំណាយប្រាក់បៀវត្សរបស់អភិបាល អភិបាលរងនៃគណៈអភិបាលក្រុង ស្រុក

គ). ចំណាយប្រាក់បៀវត្សរបស់បុគ្គលិករដ្ឋបាលក្រុង ស្រុកផ្អែកតាមចំនួនបុគ្គលិកនៃរដ្ឋបាលក្រុង ស្រុកនីមួយៗ ដែលកំណត់ដោយក្រសួងមហាផ្ទៃ

ឃ). ធនធានសម្រាប់ចំណាយប្រតិបត្តិការរដ្ឋបាលផ្សេងៗត្រូវបែងចែកទៅឲ្យរដ្ឋបាលក្រុង ស្រុកនីមួយៗ តាមការគណនាដោយផ្អែកលើសន្ទស្សន៍ដូចខាងក្រោម ÷

- ចំនួន ៤០ភាគរយ ជាចំណែកស្មើគ្នាត្រូវបានបែងចែកក្នុងទំហំចំនួនស្មើៗគ្នាសម្រាប់រដ្ឋបាលក្រុង ស្រុកនីមួយៗ
- ចំនួន ៣០ភាគរយ ត្រូវបានបែងចែកទៅតាមសមាមាត្រនៃចំនួនសមាជិកក្រុមប្រឹក្សា និងចំនួនសមាជិកគណៈអភិបាលនៃរដ្ឋបាលក្រុង ស្រុកនីមួយៗ
- ចំនួន ៣០ភាគរយ ត្រូវបានបែងចែកទៅតាមសមាមាត្រនៃចំនួនមន្ត្រីបុគ្គលិកនៃរដ្ឋបាលក្រុង ស្រុកនីមួយៗ

២). ធនធាននៃសមាសភាគអភិវឌ្ឍន៍មូលដ្ឋានត្រូវបានវិភាជទៅឱ្យរដ្ឋបាលក្រុង ស្រុកនីមួយៗ តាមការគណនាដោយផ្អែកលើសន្ទស្សន៍ដូចខាងក្រោម ÷

ក). ចំនួន ៤០ភាគរយ ជាចំណែកស្មើគ្នាត្រូវបានបែងចែកក្នុងទំហំចំនួនស្មើៗគ្នាសម្រាប់រដ្ឋបាលក្រុង ស្រុកនីមួយៗ

ខ). ចំនួន ២០ភាគរយ ត្រូវបានបែងចែកទៅតាមសមាមាត្រនៃចំនួនប្រជាជននៃរដ្ឋបាលក្រុង ស្រុកនីមួយៗដោយផ្អែកតាមទិន្នន័យផ្លូវការរបស់ក្រសួងផែនការ

គ). ចំនួន ៤០ភាគរយ ត្រូវបានបែងចែកទៅតាមសមាមាត្រនៃសន្ទស្សន៍ភាពក្រីក្រដោយផ្អែកតាមទិន្នន័យផ្លូវការរបស់ក្រសួងផែនការ។

លក្ខណៈវិនិច្ឆ័យ និងចំនួនភាគរយនៃសន្ទស្សន៍នីមួយៗសម្រាប់ធ្វើការបែងចែកធនធានសមាសភាគអភិវឌ្ឍន៍មូលដ្ឋានអាចត្រូវបានពិនិត្យ និងកែលម្អឡើងវិញនាពេលមួយសមស្របក្រោមហេតុផលនៃយុត្តិកម្មគោលនយោបាយដើម្បីធានាបាននូវសមធម៌នៃការបែងចែកធនធានដល់រដ្ឋបាលក្រុង ស្រុកនីមួយៗ។

**មាត្រា ៧.-**

រដ្ឋបាលក្រុង ស្រុកអាចប្រើប្រាស់ធនធានដែលផ្ទេរពីមូលនិធិក្រុង ស្រុកដើម្បីផ្តល់ហិរញ្ញប្បទានដល់ចំណាយចំណែកណាមួយបានលុះត្រាតែចំណាយទាំងនោះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងថវិកាក្រុង ស្រុកដែលបានអនុម័ត និងមិនផ្ទុយនឹងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងច្បាប់និងលិខិតបទដ្ឋាននានាដទៃទៀតដែលមានជាធរមាន។

១).ការប្រើប្រាស់ធនធានមូលនិធិនៃសមាសភាគរដ្ឋបាលទូទៅ ÷

ក).ចំណាយចរន្តទាំងឡាយដែលពាក់ព័ន្ធទៅនឹងកិច្ចប្រតិបត្តិការរដ្ឋបាលក្រុង ស្រុក

ខ).ចំណាយមូលធនដែលពាក់ព័ន្ធទៅនឹងកិច្ចអភិវឌ្ឍ ឬលទ្ធកម្មលើអចលនទ្រព្យ ដូចជាអគារ បរិក្ខារការិយាល័យគ្រឿងសង្ហារឹមមធ្យោបាយដឹកជញ្ជូនសម្រាប់ប្រើប្រាស់ក្នុងបុព្វហេតុរដ្ឋបាល។

២).ការប្រើប្រាស់ធនធានមូលនិធិនៃសមាសភាគអភិវឌ្ឍន៍មូលដ្ឋាន ÷

ក).ចំណាយចរន្តទាំងឡាយដែលពាក់ព័ន្ធទៅនឹងការផ្តល់សេវាមូលដ្ឋាន កិច្ចប្រតិបត្តិការហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន និងបរិក្ខារផ្សេងៗទៀតដែលត្រូវបានប្រើប្រាស់សម្រាប់ការផ្តល់សេវាទាំងនោះ។

ខ).ចំណាយមូលធនដែលពាក់ព័ន្ធទៅនឹងការវិនិយោគក្នុងកិច្ចអភិវឌ្ឍន៍មូលដ្ឋាន។

ការប្រើប្រាស់ធនធាននៃមូលនិធិសមាសភាគក្នុងចំណុចទី១ និងចំណុចទី២ ខាងលើនេះ គឺជាឆន្ទានុសិទ្ធិរបស់រដ្ឋបាលក្រុង ស្រុកនីមួយៗដែលត្រូវបានរៀបចំតាមចំណាត់ថ្នាក់នៃមាតិកាថវិកាដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា ៨.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវបោះផ្សាយអាណត្តិឧបត្ថម្ភធនជូនមូលនិធិក្រុង ស្រុកជា ០៤(បួន)លើកសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំតាមកម្មវិធីដូចខាងក្រោម ÷

- លើកទី១÷ ២៥ ភាគរយ នៃមូលនិធិសរុបនៅដើមត្រីមាសទី១
- លើកទី២÷ ២៥ ភាគរយ នៃមូលនិធិសរុបនៅដើមត្រីមាសទី២
- លើកទី៣÷ ២៥ ភាគរយ នៃមូលនិធិសរុបនៅដើមត្រីមាសទី៣
- លើកទី៤÷ ២៥ ភាគរយ នៃមូលនិធិសរុបនៅដើមត្រីមាសទី៤

## ជំពូកទី៤
## អន្តរប្បញ្ញត្តិ

**មាត្រា ៩.-**

រដ្ឋបាលក្រុង ស្រុកត្រូវយោងអតិរេកថវិកានៅដំណាច់ឆ្នាំនីមួយៗ ទៅប្រើប្រាស់សម្រាប់ហិរញ្ញប្បទានដល់ចំណាយអភិវឌ្ឍមូលដ្ឋាននៃថវិកាឆ្នាំបន្តបន្ទាប់ ចាប់ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣។

ចាប់ពីឆ្នាំ២០២៤តទៅ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវពិនិត្យ និងសម្រេចលើការប្រើប្រាស់អតិរេកថវិការបស់រដ្ឋបាលក្រុង ស្រុកបន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**មាត្រា ១០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ១១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្រុមប្រឹក្សាខេត្ត អភិបាលនៃគណៈអភិបាលខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក និងអភិបាលនៃគណៈអភិបាលក្រុង ស្រុកទាំងអស់ ត្រូវទទួលខុសត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ៕

ថ្ងៃ ពុធ ១១ រោច ខែចេត្រ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មេសា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល ÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ